ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៨.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់គាំទ្រគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងសាកល
(Global Deal Initiative)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់គាំទ្រគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងសាកល ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២- ឯកឧត្តម **អ៊ុច បូរិទ្ធ** | រដ្ឋលេខាធិការ<br>នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣- ឯកឧត្តម **ម៉ម វណ្ណៈ** | រដ្ឋលេខាធិការ<br>នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៤- ឯកឧត្តម **កែវ បូរស្ស** | អនុរដ្ឋលេខាធិការ<br>នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៥- ឯកឧត្តម **ហោ ដារិទ្ធ** | អនុរដ្ឋលេខាធិការ នៃក្រសួងផែនការ | សមាជិក |
| ៦- ឯកឧត្តម **ផាន់ ផល្លា** | អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-ឯកឧត្តម **ប្រាក់ ចាន់ធឿន** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់<br>ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅគ្រប់មុខសញ្ញា<br>នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៨- ឯកឧត្តម **ហេង សួរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ<br>នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩- ឯកឧត្តម **សេង សក្ដា** | អគ្គនាយកការងារ<br>នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០- ឯកឧត្តម **ឡៅ ហ៊ីម** | អគ្គនាយកអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ<br>នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១១-ឯកឧត្តម **ហុង ជឿន** | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ<br>នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១២-ឯកឧត្តម **ឆេស រុក្ខាផល** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន<br>គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម<br>នៅតាមគ្រប់មុខសញ្ញា | សមាជិក |
| ១៣-លោក **អ៊ុក សមវិទ្យា** | នាយកបេឡាជាតិរបបសន្តិសុខសង្គម<br>នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

**ប្រការ២ .-**

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- រៀបចំសំវាទសង្គមនៅក្នុងទីផ្សារការងារ និងទំនាក់ទំនងវិជ្ជាជីវៈ
- លើកមតិយោបល់ និងដំណើរការនៃគំនិតផ្ដួចផ្ដើមកិច្ចព្រមព្រៀងសាកលនេះ សំដៅឈានដល់ការដាក់ដំណើរការសេចក្តីប្រកាសគាំទ្រកិច្ចព្រមព្រៀងជាសាកលនេះ នៅឆ្នាំ២០១៦
- តាមដាន វិភាគ និងវាយតម្លៃការងារ នៃគំនិតផ្ដួចផ្ដើមកិច្ចព្រមព្រៀងសាកល
- ធ្វើរបាយការណ៍ប្រចាំឆ្នាំជូនប្រមុខរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងទៀត ដែលប្រធានគណៈកម្មការប្រគល់ជូន។

**ប្រការ៣ ._**

គណៈកម្មការនេះមានលេខាធិការដ្ឋានមួយជាជំនួយការ ចេញដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ៤ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងផែនការ ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ៤
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ